

## សូមជម្រាបសួរពី

# ប្រទេសម៉ិកស៊ិក !

ប្រទេសម៉ិកស៊ិកគឺជាប្រទេសមួយនៅទ្វីបអាមេរិកខាងជើង ។ ប្រទេសនេះមានប្រជាជនប្រហែល ១២៦ លាននាក់ ។



*សូមចូលរួមជាមួយ ម៉ាហ្គោ និង ប៉ោឡូ កាលដែលពួកគេធ្វើដំណើរជុំវិញពិភពលោក ដើម្បីរៀនសូត្រអំពីបុត្រាបុត្រីរបស់ព្រះវរបិតាសួគ៌ ។*



### វប្បធម៌បុរាណ

ប្រទេសម៉ិកស៊ិកមានអគារជាច្រើនដែលសាងសង់ដោយមនុស្សជំនាន់ដើម ។ រៀងរាល់ឆ្នាំ មនុស្សរាប់លាននាក់មកលេងពីរ៉ាមីត ម៉ាយ៉ាន នៅឈីឆេន អ៊ីតហ្សា ក្នុងរដ្ឋយូកាតាន ។

### ព្រះវិហារបរិសុទ្ធជាច្រើន

ប្រទេសម៉ិកស៊ិកមានព្រះវិហារបរិសុទ្ធដែលបានឧទ្ទិសឆ្លងចប់ហើយដល់ទៅ ១៣ ហើយនឹងមានច្រើនទៀតដែលកំពុងតែសាងសង់ ។ កុមាររូបនេះបានទៅព្រះវិហារបរិសុទ្ធ វៀរ៉ាគ្រូស ។





### ការជួបជុំគ្នា

នេះគឺជាអគារសាសនាចក្រនៅក្នុងប្រទេសម៉ិកស៊ិក ។ ប្រទេសម៉ិកស៊ិកមានសមាជិកសាសនាចក្រជិត ១.៥ លាននាក់—ជាប្រទេសទីពីរដែលមានសមាជិកច្រើនជាងប្រទេសនានាក្នុងពិភពលោក !



### **Baile Folklórico** ( របាំប្រជាប្រិយ )

ផ្នែកជាច្រើននៃប្រទេសម៉ិកស៊ិកមានតន្ត្រី របាំ និងសម្លៀកបំពាក់តាមបែបផ្ទាល់ខ្លួនរបស់ពួកគេ ។ កុមារីម្នាក់នេះស្លៀកសម្លៀកបំពាក់ប្រពៃណីមកពី ឈីប៉ាស ។

### អាហារសម្រន់ដ៏ឆ្ងាញ់ពិសា

ខ្វាកកាម៉ូលី ( Guacamole ) គឺជាគ្រឿងជ្រលក់ម្យ៉ាងធ្វើពីផ្លែប៊ឺរ ។ គេញ៉ាំវាដោយដាក់នៅលើថាកូ នៅក្នុងសាឡាដ ឬជាមួយបន្ទះនំឈីបពោត ។*Delicioso* !

